ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្តាល

សំណុំរឿងព្រហ្មទណ្ឌលេខ ២១៦២ អ.ក
ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២០
សាលក្រមលេខ ១១៤ ស.ព្រ.ណ/២២
ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២២

# តាងនាមប្រជារាស្ត្រខ្មែរ

បានបើកសវនាការជាសាធារណៈ នៅសាលាដំបូងខេត្តកណ្តាល ។
កាលបរិច្ឆេទសវនាការ ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២២ ។
កាលបរិច្ឆេទនៃការប្រកាសសាលក្រមថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២២ ។

## ចៅក្រមជំនុំជម្រះ

លោក [redacted] ចៅក្រមជំនុំជម្រះ

## តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារង

## ក្រឡាបញ្ជី

លោក [redacted] ក្រឡាបញ្ជីសវនាការ

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ ២១៦២ អ.ក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២០ ដែលមានជនជាប់ចោទ

១. ឈ្មោះ [redacted] ាន់លីដា ហៅ ទូច ភេទស្រី អាយុ ២៦ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តកណ្តាល ទីលំនៅបច្ចុប្បន្ននៅភូមិក្បាលកោះ សង្កាត់កោះអន្លង់ចិន ក្រុងតាខ្មៅ ខេត្តកណ្តាល ម្តាយឈ្មោះ [redacted] យុតធី (រ) ប្តីឈ្មោះ [redacted] វណ្ណារ៉ា (រ) ទោសពីមុន គ្មាន ។ (ក្រៅឃុំ)

២. ឈ្មោះ [redacted] យុតធី ភេទស្រី អាយុ ៥៥ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើតនៅភូមិក្ប [redacted] ខេត្តកណ្តាល ទីលំនៅបច្ចុប្បន្ននៅភូមិក្បាលកោះ សង្កាត់កោះអន្លង់ចិន ក្រុងតាខ្មៅ ខេត្តកណ្តាល ទោសពីមុន គ្មាន ។ (ក្រៅឃុំ)

៣. ឈ្មោះ [redacted] សារឿត ហៅ ទុយ ភេទប្រុស អាយុ ៣១ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តបាត់ដំបង ទីលំនៅបច្ចុប្បន្ននៅភូមិក្បាលកោះ សង្កាត់កោះអន្លង់ចិន ក្រុងតាខ្មៅ ខេត្តកណ្តាល ទោសពីមុន គ្មាន ។ (ក្រៅឃុំ)

៤. ឈ្មោះ [redacted] ស្រីលីន ភេទស្រី អាយុ ៤៨ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើតនៅភូមិក្បា [redacted] ខេត្តក្រចេះ ទីលំនៅបច្ចុប្បន្ននៅភូមិ



ក្រឡាបញ្ជីលោក [redacted]

ខ្ពបវែង សង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ ខេត្តកណ្តាល ប្តីឈ្មោះ [redacted] ទូច (រ) ទោសពីមុនគ្មាន ។ (ក្រៅឃុំ)

៥. ឈ្មោះ [redacted] ទូច ភេទប្រុស អាយុ ៥៤ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តកណ្តាល ទីលំនៅបច្ចុប្បន្ននៅភូមិខ្ពបវែង សង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ ខេត្តកណ្តាល ប្រពន្ធឈ្មោះ [redacted] ស្រីលីន (រ) ទោសពីមុនគ្មាន ។ (ក្រៅឃុំ)

៦. ឈ្មោះ [redacted] ស្រីឡាង ហៅ ចៃ ភេទស្រី អាយុ ២៤ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើតនៅភូ [redacted] ខេត្តកណ្តាល ទីលំនៅបច្ចុប្បន្ននៅភូមិខ្ពបវែង សង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] ទូច (រ) ម្តាយឈ្មោះ [redacted] ស្រីលីន (រ) ទោសពីមុន គ្មាន ។ (ក្រៅឃុំ)

ត្រូវបានជាប់ចោទពី **បទហិង្សាដោយចេតនា (ទៅវិញទៅមក)** ប្រព្រឹត្តនៅភូមិក្បាលកោះ សង្កាត់កោះអន្លង់ចិន ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២០ ជាបទល្មើសព្រហ្មទណ្ឌ ដែលមានចែង និង ផ្តន្ទាទោសស្របតាមបញ្ញត្តិមាត្រា **២១៧** នៃក្រមព្រហ្មទណ្ឌ ។

ដោយមានលោកមេធាវី [redacted] ការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ទូច ឈ្មោះ **ពៅ** ស្រីលីន និង ឈ្មោះ [redacted] ស្រីឡាង ។

ដោយមានលោកមេធាវី [redacted] ការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ទូច ភេទប្រុស និង ឈ្មោះ [redacted] ស្រីលីន ។

- **បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់លេខ ១១១ ដប.ជរ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ ២០២១ ។

## អង្គហេតុដែលបានចោទប្រកាន់បញ្ជូនមកជំនុំជម្រះ

កាលពីថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង ១៤ និង ០០នាទី មានករណីហិង្សាដោយចេតនាមួយកើតឡើង ស្ថិតនៅភូមិក្បាលកោះ សង្កាត់កោះអន្លង់ចិន ក្រុងតាខ្មៅ ខេត្តកណ្តាល ។ ដំណើររឿងមានដូចតទៅ នៅថ្ងៃកើតហេតុឈ្មោះ [redacted] វ៉ាន់លីដា ហៅ ទូច ឈ្មោះ [redacted] យុតធី ឈ្មោះ [redacted] សារឿត ហៅ ទុយ និង ឈ្មោះ [redacted] វណ្ណារ៉ា ហៅ ក្តាម បាននាំគ្នាជីកដាំបង្គោលថ្មធ្វើជារបងកាត់ទទឹងដី ខាងត្បូងជាប់មាត់ទន្លេចូលមកក្នុងដីរបស់ឈ្មោះ [redacted] ទូច លុះបានបន្តិចឈ្មោះ [redacted] ទូច ក៏បានទៅហាមឃាត់ជាមួយប្រពន្ធឈ្មោះ [redacted] ស្រីលីន និង កូនឈ្មោះ [redacted] ស្រីឡាង ហៅ ចៃ ដោយឈ្មោះ [redacted] ទូច បានយកប៉ែលកាយដីលុបរណ្តៅសម្រាប់ដាក់បង្គោល ចំណែកឈ្មោះ [redacted] វ៉ាន់លីដា ហៅ ទូច មិនស្តាប់នៅតែបន្តធ្វើ និង បាននាំគ្នាលើកបង្គោលទៀត ហើយឈ្មោះ [redacted] ទូច ខឹងក៏បានចូលធាក់បង្គោលឱ្យដួល ចំណែកឈ្មោះ [redacted] ស្រីលីន បានទាស់សម្តីជាមួយឈ្មោះ [redacted] វ៉ាន់លីដា រួចក៏បានវាយប្រតាយប្រតប់គ្នាទៅវិញទៅមក បណ្តាលឱ្យឈ្មោះ **ពៅ** ស្រីលីន ដួលផ្ងាក្រោយទៅលើដី ឃើញដូច្នេះឈ្មោះ [redacted] ស្រីឡាង ហៅ ចៃ ក៏បានស្ទុះទៅជួយម្តាយរបស់ខ្លួនឈ្មោះ [redacted] ស្រីលីន ហើយវាយប្រតាយប្រតប់ចាប់បោចសក់ក្បាលគ្នាជាមួយឈ្មោះ [redacted] វ៉ាន់លីដា ហើយ



Scanned with CamScanner

ឈ្មោះ [redacted] សារឿត ហៅ ទុយ ត្រូវជាប្ដីរបស់ឈ្មោះ [redacted] វ៉ាន់លីដា ក៏បានចូលមកជួយវាយទៅលើឈ្មោះ [redacted] ស្រីឡាង ហៅ ចៃ ពីក្រោយត្រូវចំកចំនួន ០២ដៃ ។ ឃើញដូច្នេះ ឈ្មោះ [redacted] យុតធី ក៏បានជួយវាយប្រតាយប្រតប់ជាមួយឈ្មោះ [redacted] ស្រីលីន ហើយឈ្មោះ [redacted] ទូច ក៏បានចូលមកច្រានឈ្មោះ [redacted] យុតធី ចេញបណ្ដាលឱ្យដួល ហើយឈ្មោះ [redacted] ទូច និង ឈ្មោះ [redacted] វណ្ណារ៉ា ហៅ ក្ដាម បានឈ្លោះប្រកែកគ្នា និង មានកាន់កាំបិតផ្គាក់ និង ប៉ែលនៅនឹងដៃរៀងៗខ្លួន ។

## ដំណើរការនៃកិច្ចពិភាក្សាដេញដោល

១. ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] វ៉ាន់លីដា បានឆ្លើយថា ៖ ឈ្មោះ [redacted] ស្រីលីន បានកាន់ដំបងវាយពីក្រោយខ្នងឈ្មោះ [redacted] ទូច ហើយកាន់ប៉ែលយាររកវ៉ៃ កូនម្នាក់ឈ្មោះ [redacted] ចៃ និង វាយខ្ញុំបោចសក់ ។ ឈ្មោះ [redacted] ស្រីលីន និង ឈ្មោះ ស្រីឡាង វាយអូសខ្ញុំចំងាយ ១៥ម៉ែត្រ ។ ច្រានម្ដាយខ្ញុំឈ្មោះ [redacted] យុតធី ដួលផ្ងារក្រោយ ។ ខ្ញុំបានតដៃវិញដែរ ប៉ុន្តែតិចតួច ខ្ញាខ្ញុំ ២នាក់មានឈ្មោះ [redacted] យុតធី និង ខ្ញុំ ដោយឡែកអ្នកដែលមកធ្វើបេងមិនបានចូលរួមទេ ។ ឈ្មោះ [redacted] ស្រីលីន ចូលមកវាយខ្ញុំមុន ។ ខ្ញុំរបួសចង្កា និង ក្រោយខ្នង ។

២. ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ស្រីលីន បានឆ្លើយថា ៖ ខ្ញុំប្រុងទាញឈ្មោះ [redacted] វ៉ាន់លីដា ពីក្រោយ ប៉ុន្តែមិនទាន់បានទាញផង ក៏ត្រូវបានឈ្មោះ [redacted] លីដា វាយកែងដៃ បន្ទាប់មកខ្ញុំសន្លប់បាត់ទៅ ។ ខ្ញុំមិនដឹងថាមានរឿងអ្វីកើតឡើងទៀតទេ ពេលដឹងខ្លួនវិញឃើញចាប់ផ្ដើមប្រតាយប្រតប់គ្នា ។ ខ្ញាខ្ញុំបីនាក់មានឈ្មោះ [redacted] ទូច ឈ្មោះ [redacted] ស្រីឡាង ។ ខ្ញាគេមានឈ្មោះ [redacted] យុតធី និង ឈ្មោះ [redacted] លីដា និង ពីរនាក់ផ្សេងទៀត ។ ខ្ញុំបានកាន់បំពង់ទីបបូនជ្រុងវាយប្រតាយប្រតប់គ្នា ។

៣. ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ស្រីឡាង បានឆ្លើយថា ៖ ម្ដាយខ្ញុំចូលទៅឃាត់ឈ្មោះ [redacted] វ៉ាន់លីដា ហើយឈ្មោះ [redacted] វ៉ាន់លីដា វាយកែងដៃហើយសន្លប់ ។ បន្ទាប់មកខ្ញុំបានបោចសក់ឈ្មោះ [redacted] វ៉ាន់លីដា ហើយឈ្មោះ [redacted] សារឿត បានយកដៃវាយខ្ញុំពីក្រោយ ក៏ប្រតាយប្រតប់គ្នា ។

៤. ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ទូច បានឆ្លើយថា ៖ ប្រពន្ធឈ្មោះ [redacted] ស្រីលីន ចូលទៅឃាត់ គ្មានបំណងវាយទេ តែឈ្មោះ [redacted] វ៉ាន់លីដា ដាក់មួយកែងដៃសន្លប់ ។ ឈ្មោះ [redacted] យុតធី ស្ទុះទៅវាយប្រពន្ធខ្ញុំ ។ ខ្ញុំកាន់ប៉ែលគ្មានបំណងវាយទេ ។ ខ្ញុំឃើញកូនខ្ញុំឈ្មោះ [redacted] ស្រីឡាង បោចសក់គ្នា ឈ្មោះ [redacted] សារឿត ចូលវាយពីក្រោយ ខ្ញុំក៏បានឃាត់ឈ្មោះ [redacted] សារឿត មិនឱ្យវាយបន្តទៀត ហើយក៏បញ្ចប់ទៅ ។

៥. ស្ដាប់ចម្លើយសាក្សីឈ្មោះ [redacted] វណ្ណារ៉ា បានឆ្លើយថា ៖ ឈ្មោះ [redacted] ស្រីលីន និង ឈ្មោះ [redacted] ស្រីឡាង បានធាក់ឈ្មោះ [redacted] វ៉ាន់លីដា ដួលនៅនឹងដី ហើយប្រតាយប្រតប់គ្នា ។ ឈ្មោះ [redacted] ទូច ធាក់បង្គោល ដួលមនុស្ស និង គ្មានកាន់ដំបងវាយទេ ។ ឈ្មោះ [redacted] ស្រីលីន នៅពីក្រោយបោចសក់ទាញក្បាលឈ្មោះ [redacted] វ៉ាន់លីដា ។



ក្រឡាបញ្ជីលោ[redacted]

Scanned with CamScanner

៦. ស្តាប់ចម្លើយសាក្សីឈ្មោះ [redacted] យៀង បានឆ្លើយថា ក្នុងរឿងនេះ ស្រាប់តែឃើញឈ្មោះ [redacted] ស្រីលីន ផ្ទាផើង ដោយមិនដឹងមូលហេតុ ហើយចាប់ផ្តើមវាយប្រតាយប្រតប់គ្នា ។

៧. តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា ៖ ក្រោយការឆ្លងកាត់ការពិភាក្សាដេញដោល ឃើញថាជនជាប់ចោទបានប្រព្រឹត្តបទហិង្សាដោយចេតនា ។ តំណាងអយ្យការសុំរក្សាបទចោទប្រកាន់នៅដដែល សុំឱ្យតុលាការពិនិត្យ និង ពិចារណាតាមនីតិវិធី ។

៨. លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ទូច ឈ្មោះ [redacted] ស្រីលីន និង ឈ្មោះ [redacted] ស្រីឡាង បានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា ៖ ការចោទកូនក្តីខ្ញុំប្រព្រឹត្តអំពើហិង្សាជារឿងមិនត្រឹមត្រូវទេ ។ រឿងនេះ កូនក្តីខ្ញុំមានសាលក្រមរួចហើយ ។ អាជ្ញាអស់ជំនុំនៃអង្គហេតុ (មូលហេតុនៃអំពើហិង្សាកើតឡើងរឿងដីធ្លី) ។ រឿងអង្គហេតុតែមួយ ទីកន្លែង និង ពេលវេលាដូចគ្នា ។ កូនក្តីខ្ញុំមិនអាចប្រកាសទោសទៀតទេ ប៉ុន្តែមិនទាន់មានអាជ្ញាអស់ជំនុំលើឈ្មោះ [redacted] វ៉ាន់លីដា ឈ្មោះ [redacted] យុតធី និង ឈ្មោះ [redacted] សារឿត ទេ ។ ម្យ៉ាងវិញទៀត ជាគោលការណ៍មិនជំនុំជម្រះពីរដងលើអង្គហេតុតែមួយទេ ។ ស្នើសុំឱ្យកូនក្តីខ្ញុំរួចខ្លួនពីបទចោទស្នើសុំឱ្យផ្តន្ទាទោសឈ្មោះ [redacted] វ៉ាន់លីដា ឈ្មោះ [redacted] សារឿត និង ឈ្មោះ [redacted] យុតធី ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ
-ក្រោយពីបានស្តាប់សម្តីចុងក្រោយរបស់ជនជាប់ចោទ
-ក្រោយពីបានពិនិត្យភស្តុតាងលើសំណុំរឿងនេះ

## សំអាងហេតុ

១. យោងតាមចម្លើយរបស់ជនជាប់ចោទ និង ភស្តុតាងនានា អាចបញ្ជាក់បានថា ជនជាប់ចោទបានវាយប្រតាយប្រតប់គ្នាដោយសារទំនាស់ការបោះបង្គោលដី ដែលអង្គហេតុនេះជាអង្គហេតុតែមួយ ដែលមានទីកន្លែងពេលវេលាថ្ងៃខែឆ្នាំតែមួយ ជាមួយសំណុំរឿងផ្សេងដែលត្រូវបានតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] ទូច (ស្រី ទូច) ឈ្មោះ [redacted] ស្រីលីន និង ឈ្មោះ [redacted] ស្រីឡាង ដែលមានសាលក្រមលេខ ០៤៥ (ណ) ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២១ ។ ហេតុនេះតាមគោលការណ៍អាជ្ញាអស់ជំនុំ តុលាការមិនអាចសម្រេចសេចក្តីចំពោះអង្គហេតុដែលត្រូវបានផ្តន្ទាទោសរួចជាស្ថាពរ លើជនជាប់ចោទឈ្មោះ [redacted] ទូច (ស្រី ទូច) ឈ្មោះ [redacted] ស្រីលីន និង ឈ្មោះ [redacted] ស្រីឡាង ទៀតបានឡើយ ។ ដូចនេះ តុលាការយល់ឃើញថា បញ្ឈប់នីតិវិធីបណ្តឹងព្រហ្មទណ្ឌ លើជនជាប់ចោទឈ្មោះ [redacted] ទូច ឈ្មោះ [redacted] ស្រីលីន ឈ្មោះ [redacted] ស្រីឡាង ស្របតាមបញ្ញត្តិមាត្រា ៧ ក្រមនីតិវិធីព្រហ្មទណ្ឌ ។

២. យោងតាមចម្លើយរបស់ជនជាប់ចោទ និង ភស្តុតាងនានា អាចបញ្ជាក់បានថា ជនជាប់ចោទឈ្មោះ [redacted] យុតធី គ្រាន់តែចូលទៅឃាត់តែប៉ុណ្ណោះ មិនបានចូលរួមប្រតាយប្រតប់ជាមួយជនជាប់ចោទផ្សេងទៀតទេ ហេតុនេះពុំមានវត្តមាននៃបទល្មើសដែលបង្កឡើងដោយជនជាប់ចោទ



Scanned with CamScanner

ឈ្មោះ [redacted] យុតធី ទេ ។ ដូចនេះ តុលាការយល់ឃើញថា គប្បីឱ្យជនជាប់ចោទឈ្មោះ [redacted] យុតធី រួចខ្លួនពីបទចោទប្រកាន់ ។

៣. យោងតាមចម្លើយរបស់ជនជាប់ចោទ និង ភស្តុតាងនានា ឃើញថា ជនជាប់ចោទមានការឈ្លោះទាស់គ្នាដោយសារការដាំបង្គោលរបងកាត់ទទឹងដី បង្កឱ្យមានការវាយប្រតាយប្រតប់គ្នាទៅវិញទៅមករវាងជនជាប់ចោទឈ្មោះ [redacted] វ៉ាន់លីដា និង ឈ្មោះ [redacted] សារឿត ជាមួយជនជាប់ចោទឈ្មោះ [redacted] ស្រីលីន ឈ្មោះ [redacted] ទូច និង ឈ្មោះ [redacted] ស្រីឡាង និង បង្ករឱ្យមានរបួសស្នាម ។ ដូចនេះ តុលាការយល់ឃើញថា ជនជាប់ចោទឈ្មោះ [redacted] វ៉ាន់លីដា និង ឈ្មោះ [redacted] សារឿត បានប្រព្រឹត្តបទហិង្សាដោយចេតនា ប្រាកដមែន ដោយមានភស្តុតាងផ្សេងៗ ស៊ីសង្វាក់គ្នា ។

៤. តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា សុំរក្សាការចោទប្រកាន់នៅដដែល ដោយមូលហេតុមានភស្តុតាងស៊ីសង្វាក់គ្នា ។ តុលាការនឹងពិនិត្យ និង ពិចារណាសម្រេចស្របទៅតាមអង្គហេតុ និង អង្គច្បាប់ ។

៥. បន្ទាប់ពីថ្លឹងថ្លែងកាត់ការពិភាក្សាដេញដោល យោងសំអាងហេតុទី២ និង ការពិនិត្យនូវភស្តុតាងនានាក្នុងសំណុំរឿង អាចបញ្ជាក់បានថា ជនជាប់ចោទឈ្មោះ [redacted] **យុតធី** ពុំបានប្រព្រឹត្ត **បទហិង្សាដោយចេតនា (ទៅវិញទៅមក)** ប្រព្រឹត្តនៅភូមិក្បាលកោះ សង្កាត់កោះអន្លង់ចិន ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២០ ជាបទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្តន្ទាទោសស្របតាមបញ្ញត្តិមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ នោះទេ ។

៦. បន្ទាប់ពីថ្លឹងថ្លែងកាត់ការពិភាក្សាដេញដោល និង ការពិនិត្យនូវភស្តុតាងនានាក្នុងសំណុំរឿង អាចបញ្ជាក់បានថា ជនជាប់ចោទឈ្មោះ [redacted] **វ៉ាន់លីដា** និង ឈ្មោះ [redacted] **សារឿត** បានប្រព្រឹត្ត **បទហិង្សាដោយចេតនា (ទៅវិញទៅមក)** ប្រព្រឹត្តនៅភូមិក្បាលកោះ សង្កាត់កោះអន្លង់ចិន ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២០ ជាបទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្តន្ទាទោសស្របតាមបញ្ញត្តិមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ ។

## ហេតុដូច្នេះសម្រេច

១. បញ្ឈប់នីតិវិធីបណ្តឹងព្រហ្មទណ្ឌលើ

   ក. ឈ្មោះ [redacted] ស្រីលីន ភេទស្រី អាយុ ៤៨ឆ្នាំ

   ខ. ឈ្មោះ [redacted] ទូច ភេទប្រុស អាយុ ៥៤ឆ្នាំ

   គ. ឈ្មោះ [redacted] ស្រីឡាង ហៅ ចៃ ភេទស្រី អាយុ ២៨ឆ្នាំ

ពី **បទហិង្សាដោយចេតនា** ប្រព្រឹត្តនៅភូមិក្បាលកោះ សង្កាត់កោះអន្លង់ចិន ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២០ ជាបទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្តន្ទាទោសស្របតាមបញ្ញត្តិមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ ។

២. ឱ្យឈ្មោះ [redacted] **យុតធី** ភេទស្រី អាយុ ៥៥ឆ្នាំ រួចខ្លួនពី **បទហិង្សាដោយចេតនា** ប្រព្រឹត្តនៅភូមិក្បាលកោះ សង្កាត់កោះអន្លង់ចិន ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី២១ ខែកក្កដា ឆ្នាំ



(ក្រឡាបញ្ជីលោក [redacted]ណា)

២០២០ ជាបទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្ដន្ទាទោសស្របតាមបញ្ញត្តិមាត្រា ២១៧ នៃ ក្រមព្រហ្មទណ្ឌ ។

៣. ផ្ដន្ទាទោស

ក. ឈ្មោះ [redacted] វ៉ាន់លីដា ហៅ ទូច ភេទស្រី អាយុ ២៦ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ០១ឆ្នាំ ប៉ុន្តែទោសនេះត្រូវព្យួរធម្មតា

ខ. ឈ្មោះ [redacted] សារឿត ភេទប្រុស អាយុ ៣១ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ០១ ឆ្នាំ ប៉ុន្តែទោសនេះត្រូវព្យួរធម្មតា

ពី បទហិង្សាដោយចេតនា ប្រព្រឹត្តនៅភូមិក្បាលកោះ សង្កាត់កោះអន្លង់ចិន ក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២០ ជាបទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្ដន្ទាទោសស្រប តាមបញ្ញត្តិមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ ។

សាលក្រមនេះ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] វ៉ាន់លីដា ឈ្មោះ [redacted] សារឿត ឈ្មោះ [redacted] ស្រីលីន ឈ្មោះ [redacted] ទូច ឈ្មោះ [redacted] ស្រីឡាង និង កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] យុតធី ។ ទុកសិទ្ធិប្ដឹងទាស់ និង ប្ដឹងឧទ្ធរណ៍ តាមកំណត់ច្បាប់ ។

ថ្ងៃសុក្រ ១៣រោច ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

កណ្ដាល, ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

ហត្ថលេខា និង ត្រា [redacted]

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និង ត្រា [redacted]

---

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃសុក្រ ១៣រោច ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

កណ្ដាល, ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២២

បានឃើញ

**ចៅក្រមជំនុំជម្រះ**

[redacted]

**ក្រឡាបញ្ជី**

[redacted]